## រឿងទី៨៖ អ៊ីសាក និងរេបិកា

**ខគម្ពីរ៖ លោកុប្បត្តិ ២៤៖៦៧**

លោកអ៊ីសាកនាំនាងរេបិកាចូលទៅក្នុងជំរំ ដែលលោកស្រីសារ៉ា ជាម្ដាយ ធ្លាប់នៅកាលពីមុន។ គាត់បានយកនាងធ្វើជាភរិយា គាត់ស្រឡាញ់ថ្នាក់ថ្នមនាង ហើយនាងក៏ធ្វើឲ្យគាត់បានធូរស្បើយពីទុក្ខ ក្រោយពីម្ដាយស្លាប់។

អប្រាហាំបានសម្រេចឱ្យអ៊ីសាករៀបការ។ អប្រាហាំបាននឹកចាំពីស្រុកកំណើតរបស់ខ្លួនដែលបានចាកចេញមកអស់ពេលជាយូរមកហើយ។

គាត់បានហៅបាវបម្រើជំស្មោះត្រង់ម្នាក់មក។

គាត់បង្គាប់ឱ្យបាវបម្រើនោះទៅហារ៉ាន រកស្ត្រីម្នាក់ដែលនឹងក្លាយជាភរិយារបស់អ៊ីសាក។

អ្នកបម្រើនោះបានធ្វើដំណើរចេញទៅទីកន្លែងដ៏ឆ្ងាយនោះ។

ទីបំផុត អ្នកបម្រើនោះ ក៏បានទៅដល់ហារ៉ាននៅពេលល្ងាច។

ធ្វើដំណើរមកពីឆ្ងាយ ហត់អស់កម្លាំងពេក អ្នកបម្រើនោះក៏បានឈប់សម្រាកបន្តិចក្បែរអណ្ដូងនៅក្រៅទីក្រុង។

អ្នកបម្រើនោះបានលុតជង្គង់នៅក្បែរអណ្ដូងនោះអធិស្ឋានទៅព្រះជាម្ចាស់ថា៖

«ព្រះអម្ចាស់អើយ ដ្បិតពេលនេះមានស្រីៗជាច្រើនចេញមកដងទឹកអណ្ដូង ចំណោមពួកនាងបើមាននាងណាម្នាក់ដងទឹកឱ្យទូលបង្គំផឹក ហើយឱ្យសត្វអូដ្ឋទាំងអស់ផឹកនោះ ទូលបង្គំនឹងដឹងថានាងជាស្ត្រីដែលទ្រង់ជ្រើសជាភរិយារបស់លោកម្ចាស់អ៊ីសាកហើយ»។ បន្តិចក្រោយមក មាននារីម្នាក់កណ្ដៀតក្អមទឹកចេញពីទីក្រុងមកអណ្ដូងទឹក។

អ្នកបម្រើបានដើរទៅជិតនារីម្នាក់នោះហើយនិយាយថា៖ «តើខ្ញុំអាចសុំទឹកនាងផឹកបន្តិចបានទេ?»



រេបិកាបានឆ្លើយទៅវិញថា៖ «លោកពិសាទឹកនេះទៅ។ ចាំខ្ញុំដងទឹកឱ្យអូដ្ឋទាំងអស់បានផឹកដែរ»។

អ្នកបម្រើដែលលឺពាក្យនោះហើយ មានការភ្ញាក់ផ្អើលជាខ្លាំង។

«អូ ព្រះជាម្ចាស់ពិតជាបានឆ្លើយតបការអធិស្ឋានរបស់ខ្ញុំហើយ ដូច្នេះ នារីម្នាក់នេះហើយដែលនឹងក្លាយជាភរិយារបស់លោកម្ចាស់អ៊ីសាកខ្ញុំ»។

នារីម្នាក់នោះមានឈ្មោះថា «រេបិកា»

អ្នកបម្រើ និងរេបិកាបានធ្វើដំណើរឆ្ពោះទៅផ្ទះរបស់អប្រាហាំ។

ពេលអ្នកបម្រើ និងរេបិកាបានទៅដល់ផ្ទះអប្រាហាំ ពេលនោះអ៊ីសាកកំពុងតែដើរនៅតាមទីវាល។

អ្នកបម្រើ បានរ៉ាយរ៉ាប់ប្រាប់ពីដំណើររឿងទាំងប៉ុន្មានដែលខ្លួនបានជួប ហើយអ៊ីសាកក៏នាំរេបិកាដើរមើលក្នុងផ្ទះ។



## សកម្មភាពទី១ សូមឆ្លើយសំណួរខាងក្រោម។

a. តើលោកអប្រាហាំនិងអ្នកបម្រើបានរកប្រពន្ធឱ្យអ្នកណា?

---

b. តើអ្នកបម្រើរបស់លោកអប្រាហាំបានទៅទីក្រុងណាដើម្បីរកប្រពន្ធឱ្យអ៊ីសាក?

---

c. សូមអានលោកុប្បត្តិ២៤៖១២-២៤ តើសញ្ញាសម្គាល់អ្វីដែលធ្វើឱ្យអ្នកបម្រើរបស់លោកអប្រាហាំដឹងថា អ្នកណាដែលនឹងក្លាយជាភរិយារបស់អ៊ីសាក?

---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ២៤៖៦៧)

> លោកអ៊ីសាកនាំនាងរេបិកាចូលទៅក្នុងជំរំ ដែលលោកស្រីសារ៉ា ជាម្ដាយ ធ្លាប់នៅកាលពីមុន។ គាត់បានយកនាងធ្វើជាភរិយា គាត់ស្រឡាញ់ថ្នាក់ថ្នមនាង ហើយនាងក៏ធ្វើឲ្យគាត់បានធូរស្បើយពីទុក្ខ ក្រោយពីម្ដាយស្លាប់។

## សកម្មភាពទី២ សូមបំពេញល្បែងផ្គុំពាក្យឆ្លង។




### ផ្ដេក

1. តើអ្នកបម្រើរបស់លោកអប្រាហាំអធិស្ឋាននៅកន្លែងណា? (លោកុប្បត្តិ២៤៖១៣)
3. គាត់និយាយមិនទាន់ទាំងចប់ផង ស្រាប់តែនាងរេបិកា ......................... ចេញពីទីក្រុងមក។ (លោកុប្បត្តិ២៤៖១៥)
4. តើអ៊ីសាកបានចាកចេញពីកន្លែងណា ទៅរស់នៅតាមតំបន់វាលរហោស្ថានណេកិប? (លោកុប្បត្តិ២៤៖៦២)
6. តើរេបិកានាងមានសម្ផស្សដូចម្ដេច? (លោកុប្បត្តិ២៤៖១៦)
9. តើពាក្យ«God Bless You» មានន័យដូចម្ដេចជាភាសាខ្មែរ?

### ឈរ

2. តើអ្នកបម្រើរបស់លោកអប្រាហាំអធិស្ឋានដូចម្ដេច? (លោកុប្បត្តិ២៤៖១៤)
5. ពេលព្រះជាម្ចាស់សម្រេចការអ្វីមួយមកយើង តើយើងគួរនិយាយទៅព្រះអង្គដូចម្ដេច?
7. បន្ទាប់ពីរៀបការជាមួយគ្នារួច តើនាងរេបិកាក្លាយជាអ្វីនឹងអ៊ីសាក?
8. តើបងប្រុសរបស់រេបិកាមានឈ្មោះអ្វី? (លោកុប្បត្តិ២៤៖២៩)
10. តើលោកម៉ូសេទទួលមរណភាពនៅអាយុប៉ុន្មាន? (ទុតិយកថា៣៤៖៧)